

## ហេតុដូចម្តេចបានជាយើងត្រូវការក្បួនខ្នាតថ្មីស្តីពីសុវត្ថិភាពនៃម្ហូបអាហារ?

នៅក្នុងឆ្នាំ១៩៩៥ រដ្ឋមន្ត្រីខាងសុខភាពរដ្ឋនិងដែនដីបានសុំអាជ្ញាធរខាងម្ហូបអាហារអូស្ត្រាលី ញ៉ូវហ្ស៊ីលែនឲ្យបង្កើតក្បួនខ្នាតសុវត្ថិភាពនៃម្ហូបអាហារជាតិដូចគ្នាទាំងអស់សំរាប់ប្រទេសអូស្ត្រាលី ។

គេបានទទួលធ្វើព្រោះថា ៖

- ក្បួនច្បាប់ដែលមានរួចមកហើយខាងអនាម័យម្ហូបអាហាររដ្ឋនិងដែនដីខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ ។
- ជួនកាលក្បួនច្បាប់ទាំងនោះហួសសម័យណាស់
- កត្តាទាំងនេះបានបង្កើតបញ្ហាជាច្រើនដល់ពាណិជ្ជកម្មម្ហូបអាហារនៅក្នុងរដ្ឋនិងដែនដីខុសៗគ្នា ។
- នេះមានន័យថាមានការចំណាយឥតប្រយោជន៍សំរាប់អ្នកប្រើប្រាស់និងពាណិជ្ជកម្ម ។

រដ្ឋមន្ត្រីក៏មានកង្វល់នឹងករិតជម្ងឺដែលបណ្តាលមកពីម្ហូបអាហារនៅក្នុងប្រទេសអូស្ត្រាលីដោយសារមានឧប្បហេតុនៃការពុលម្ហូបអាហារយ៉ាងធ្ងន់ធ្ងរ, ខ្លះបណ្តាលឲ្យស្លាប់ផង ។

ក្បួនខ្នាតថ្មីបានបង្កើតឡើងដើម្បីជួយពាណិជ្ជកម្មក្នុងការរក្សាម្ហូបអាហារឲ្យមានសុវត្ថិភាពហើយនិងបន្ថយករិតនៃជម្ងឺដែលបណ្តាលមកពីម្ហូបអាហារនៅក្នុងប្រទេសអូស្ត្រាលី ។ វាក៏មានមូលដ្ឋានលើប្រតិបត្តិនៃសុវត្ថិភាពម្ហូបអាហារសម័យថ្មីហើយនិងយកក្បួនខ្នាតអន្តរជាតិមកគិតផងដែរ ។

*សំខាន់ទៅទៀត, ក្បួនខ្នាតនេះបានបង្កើតដើម្បីធ្វើឲ្យប្រាកដថា ម្ហូបអាហារដែលយើងទិញនៅក្នុងប្រទេសអូស្ត្រាលីមានសុវត្ថិភាពនឹងបរិភោគ ។*

## ទំនាក់ទំនងសំខាន់ៗ

សាលាសង្កាត់លោកអ្នក ឬក្រុមសុខភាពសាធារណៈ:

**Queensland:**
Queensland Health Public Health Units or Environmental Health,
Tel (07) 3234 0938

**NSW:**
Food Unit, Department of Health,
Tel 02 9816 0268

**Victoria:**
Your local Environmental Health Officer,
Food Safety Victoria hotline 1300 364 352

**Tasmania:**
State Food Officer, Department of Health and Human Services,
Tel 1800 671 738

**South Australia:**
Food Branch, Department of Human Services,
Tel 08 8226 7100,
ehb@dhs.sa.gov.au

**Western Australia:**
Food Safety Section,
Department of Health, Tel 08 9388 4999

**Northern Territory:**
Territory Health Services,
Tel 08 8999 2939

**ACT:**
Food Safety Standards Project Officer,
Health Protection Service, Tel 02 6205 1700

**Australia New Zealand Food Authority**
P O Box 7186, Canberra MC ACT 2610
Tel: 02 6271 2222 Fax: 02 6271 2278

Visit the ANZFA Website: www.anzfa.gov.au
E-mail ANZFA directly: advice@anzfa.gov.au
Call the ANZFA advice line. 1300 652 166

# ក្បួនខ្នាតថ្មីស្តីពីសុវត្ថិភាពនៃម្ហូបអាហារសំរាប់ពាណិជ្ជកម្មម្ហូបអាហារនៅក្នុងប្រទេសអូស្ត្រាលី

**New Food Safety Standards for Food Business in Australia**

**Cambodian**



Commonwealth Department of Health and Aged Care

ANZFA Australia New Zealand Food Authority
TE MANA WHAKARITE KAI MŌ Ā ITEREIRIA ME AOTEAROA

ការបកប្រែភាសានេះបានទទួលការឧបត្ថម្ភទាំងស្រុងពីក្រសួងសហព័ន្ធខាងសុខភាពនិងការថែរក្សាមនុស្សចាស់



ខិតប័ណ្ណនេះបង្ហាញនូវក្បួនខ្នាតសុវត្ថិភាពនៃម្ហូបអាហារថ្មី បីជាចាំបាច់ដែលអនុវត្តចំពោះពាណិជ្ជកម្មម្ហូបអាហារ និមួយៗនៅក្នុងប្រទេសអូស្រ្តាលីដោយលើកលែងតែ ពាណិជ្ជកម្មណាដែលទាក់ទិនផ្ទាល់មុខក្នុងផលិតកម្មធាតុដើម ។

ពាណិជ្ជកម្មម្ហូបអាហារ និងអ្នកចាប់កាន់ម្ហូបអាហារត្រូវការ ដឹងអំពីតម្រូវការថ្មីដែលមានឥទ្ធិពលដល់គេ ។

ក្បួនខ្នាតថ្មីនេះគ្របសង្កត់លើ ៖
- ប្រតិបត្តិសុវត្ថិភាពម្ហូបអាហារទូទៅ;
- តម្រូវការនៃការចាប់កាន់ម្ហូបអាហារ
- បញ្ហាសុខភាព និង អនាម័យ
- បរិវេណហាង និង គ្រឿងប្រដាប់

ខិតប័ណ្ណនេះមានចុះតម្រូវការថ្មីខ្លះៗនៅក្នុងក្បួនខ្នាតហើយ និងថ្ងៃខែដែលក្បួនខ្នាតនេះបានចាប់អនុវត្តន៍នៅក្នុងរដ្ឋ និង ដែនដី ។ វាក៏ពន្យល់ប្រាប់នូវទីកន្លែងណាដែលពាណិជ្ជកម្ម អាចទៅរកពត៌មានបន្ថែមទៀត និងរាប់បញ្ចូលពត៌មានទូទៅ ស្តីពីក្បួនខ្នាតថ្មីស្តីពីសុវត្ថិភាពនៃម្ហូបអាហារ។

## តារាងពេលវេលាសំរាប់ការបង្ហាញដំបូងនៃក្បួនខ្នាតសុវត្ថិភាពនៃម្ហូបអាហារជាចាំបាច់

ក្បួនខ្នាតថ្មីអនុវត្តចាប់ពីថ្ងៃខែដូចខាងក្រោមនេះ ៖
២៨ ខែកុម្ភៈ ឆ្នាំ២០០១ ។ តម្រូវការទាំងអស់លើកលែងតែ ៖
១-តម្រូវការនៃលិខិតប្រាប់ឲ្យដឹង; ២៨ខែកុម្ភៈ ឆ្នាំ២០០២;
ហើយនិង
២-ជំនាញការ ហើយនិងជំរិះវិជ្ជានៃអ្នកចាប់កាន់ម្ហូបអាហារ;
២៨ខែកុម្ភៈ ឆ្នាំ២០០២ ។

យ៉ាងណាក៏ដោយ, ក្បួនខ្នាតថ្មីមិនបានចាប់អនុវត្តទាំងស្រុង ទេ រហូតដល់រដ្ឋនិងដែនដីកែប្រែច្បាប់ម្ហូបអាហារដើម្បី អនុម័តក្បួនខ្នាតនេះ ។

## ពេលណាក្បួនខ្នាតថ្មីនឹងត្រូវគេអនុម័តនៅក្នុងរដ្ឋ/ដែនដីខ្ញុំ?

ថ្ងៃខែដែលក្បួនខ្នាតនឹងអនុម័តមានខុសៗគ្នានៅតាមរដ្ឋនិង ដែនដី ។ នៅពេលបោះពុម្ព(ខែសីហា២០០១), វាមានច្បាប់ នៅក្នុងរដ្ឋញ៉ូវសោវែល និងគ្វីនឡែន ។ ចំពោះតំបន់ដ៏ទៃ ទៀត ចូរទាក់ទងសាលាសង្កាត់ ឬក្រសួងសុខភាព ឬ ក្រសួងកិច្ចបំរើមនុស្សលោក, ពត៌មានពិស្តារសំរាប់ទាក់ទង មាននៅចុងខិតប័ណ្ណនេះ ។

## តើខ្ញុំនឹងត្រូវធ្វើអ្វីខ្លះដែលខុសពីដើម?

ក្បួនខ្នាតថ្មីមានមូលដ្ឋានលើច្បាប់ម្ហូបអាហារចាស់ ។ ទោះបី មានតម្រូវការថ្មីខ្លះៗក៏ដោយ, ពាណិជ្ជកម្មដែលបើកធ្វើ ដោយសុវត្ថិភាពនៅពេលឥឡូវនេះហើយនិងដោយអនុលោម ទៅតាមវិន័យម្ហូបអាហារចាស់ គួរស្វែងយល់ថាការ សំរបនឹងតម្រូវការថ្មីគឺជាការងាយស្រួល ។

ម្យ៉ាងទៀត, ឲ្យតែអ្វីៗដែលគេធ្វើមានសុវត្ថិភាព ហើយនិង គេអាចបញ្ជាក់ថាវាពិតមែននោះ, ពាណិជ្ជកម្មម្ហូបអាហារខ្លះ នឹងស្វែងយល់ថាក្បួនខ្នាតថ្មីគ្រាន់បើជាងក្បួនខ្នាតចាស់ ព្រោះថាគេនឹងមានការផ្លាស់ប្តូរទៅតាមកាលៈទេសៈច្រើន ក្នុងរបៀបគេធ្វើការ ។

## តម្រូវការថ្មីសំរាប់ពាណិជ្ជកម្មម្ហូបអាហារ

ពាណិជ្ជកម្មម្ហូបអាហារនឹងត្រូវផ្តល់ឲ្យភ្នាក់ងារអនុវត្តច្បាប់ នូវពត៌មានពិស្តារសំរាប់ទាក់ទងនិងពត៌មានស្តីពីពាណិជ្ជកម្មរបស់គេ, ប្រសិនបើគេមិនទាន់ផ្តល់ពត៌មាននេះនៅឡើយដែលនៅក្រោម តម្រូវការនៃការចុះឈ្មោះដែលមានពីមុនមកហើយ ។

ពាណិជ្ជកម្មម្ហូបអាហារមានការទទួលខុសត្រូវក្នុងការធ្វើឲ្យ ប្រាកដថាម្ហូបអាហារដែលគេទិញនោះមានសុវត្ថិភាពហើយ និងសមរម្យសំរាប់គេប្រើ ។

ឧស្សាហកម្មម្ហូបអាហារ, អ្នកលក់ដុំ និងអ្នកនាំចូលដែលមិន ទាន់មានប្រព័ន្ធប្រមូលយកម្ហូបអាហារមកវិញជាលាយលក្ខ អក្សរទេនោះ ត្រូវធ្វើមួយសំរាប់ពាណិជ្ជកម្មរបស់គេ ។

ពាណិជ្ជកម្មម្ហូបអាហារនឹងត្រូវគេសង្ឃឹមថាគេធ្វើម្ហូបអាហារ តាមរបៀបនានាដែលធ្វើឲ្យប្រាកដថាមេរោគបាក់តេរីគ្រោះ ថ្នាក់នៅក្នុងកំរិតសុវត្ថិភាព ។

ពាណិជ្ជកម្មម្ហូបអាហារដែលធ្វើការជាមួយម្ហូបអាហារដែលអាច មានគ្រោះថ្នាក់ត្រូវតែមាននិងការប្រើប្រដាប់ស្ទង់កំដៅម្ហូបអាហារមួយ ។

## តម្រូវការសំរាប់អ្នកចាប់កាន់ម្ហូបអាហារ

អ្នកចាប់កាន់ម្ហូបអាហារត្រូវធ្វើឲ្យប្រាកដថានៅក្នុងករណី ណាក៏ដោយ, គេមិនចម្លងមេរោគទៅម្ហូបអាហារហើយគេ នឹងមានការទទួលខុសត្រូវច្បាស់លាស់ដែលទាក់ទិននឹង សុខភាពនិងភាពស្អាតផ្ទាល់ខ្លួន ។

អ្នកចាប់កាន់ម្ហូបអាហារត្រូវគេសង្ឃឹមថាគេមានជំនាញការ និងជំរេះវិជ្ជាទាក់ទិននឹងការងារដែលគេធ្វើ-ការហ្វឹកហ្វឺនជា ផ្លូវការមិនចាំបាច់ទេ ហើយការហ្វឹកហ្វឺននៅក្នុងការដ្ឋាន “in house” ត្រូវបានគេទទួលស្គាល់ ។





## តើមានតម្រូវការថ្មីៗដ៏ទៃទៀតឬទេ?

លក្ខខ័ណ្ឌដ៏ទៃខ្លះទៀតនៃក្បួនខ្នាតក៏ប្រហែលជាថ្មីចំពោះ ពាណិជ្ជកម្មម្ហូបអាហារនៅក្នុងរដ្ឋនិងដែនដីខ្លះៗដែរ ។ នេះ នឹងយោងទៅតាមអ្វីៗដែលបានចុះបញ្ចូលនៅក្នុងក្បួនច្បាប់ អនាម័យចាស់នៃរដ្ឋនិងដែនដី ។ ក្រសួងសុខភាពរដ្ឋនិង ដែនដីនឹងអាចផ្តល់ឲ្យពាណិជ្ជកម្មនូវពត៌មានស្តីពីការផ្លាស់ប្តូរនៅ តាមតំបន់ ។

## កម្មវិធីសុវត្ថិភាពនៃម្ហូបអាហារ

រដ្ឋនិងដែនដីខ្លះមានផែនការណ៍បញ្ចេញដំបូងនូវកម្មវិធី សុវត្ថិភាពនៃម្ហូបអាហារចំពោះថ្នាក់ពាណិជ្ជកម្មខ្លះៗ ។

ប្រសិនបើកម្មវិធីសុវត្ថិភាពនៃម្ហូបអាហារអនុវត្តនៅក្នុងរដ្ឋ ឬដែនដីរបស់លោកអ្នក, ក្រសួងសុខភាពរដ្ឋ ឬដែនដី លោកអ្នក ឬសាលាសង្កាត់លោកអ្នកនឹងប្រាប់លោកអ្នក ពីរឿងនេះ ហើយនិងអាចប្រាប់លោកអ្នកថាតើកម្មវិធីនេះ មានអនុភាពមកលើពាណិជ្ជកម្មលោកអ្នកយ៉ាងដូចម្តេច ។

## តើខ្ញុំអាចទៅរកឱវាទនៅទីណា?

ក្រសួងសុខភាពរដ្ឋនិងដែនដីនឹងធ្វើការជាមួយសាលា សង្កាត់ហើយនិងក្រុមសុខភាពសាធារណៈដើម្បីធ្វើឲ្យ ប្រាកដថាពាណិជ្ជកម្មដឹងអំពីការបញ្ចេញដំបូងនៃក្បួនខ្នាត ថ្មីនេះ ។

ពាណិជ្ជកម្មនឹងអាចសាកសួរសាលាសង្កាត់ ឬក្រុមសុខ ភាពរបស់គេរកឱវាទ នៅពេលដែលក្បួនខ្នាតនេះត្រូវបាន គេបញ្ចេញជាលើកដំបូងនៅក្នុងតំបន់របស់គេ ។

ចំពោះពត៌មានថែមទៀតស្តីពីក្បួនខ្នាតថ្មីនេះ

ចូរបើកមើលវែបសៃនៃ ANZFA :www.anzfa.gov.au
ចូរអ៊ីមែលផ្ទាល់ទៅANZFA : advice@anzfa.gov.au
ចូរទូរស័ព្ទទៅខ្សែផ្តល់ឱវាទនៃ ANZFA: 1300 652 166

*ចំពោះពត៌មានពិស្តារសំរាប់ក្រសួងសុខភាពរដ្ឋ ឬដែនដី របស់លោកអ្នក, ចូរអានអត្ថបទខាងខ្នងខិតប័ណ្ណនេះ ។*

